# ការអំពាវនាវរបស់ អ.វ.ត.ក សុំឲ្យចូលរួមជាគំនិត សម្រាប់ការផ្តួចផ្តើមធាក់ទងជនរងគ្រោះ ស្តូប រំលឹកនៅក្នុងទីក្រុងភ្នំពេញ ដោយមានឈ្មោះជនរងគ្រោះដែលស្លាប់ ដោយសារអំពើប្រល័យរបស់ខ្មែរក្រហម

*Nathan J. CHAN*

**១. គំនិត**៖ស្តូបរំលឹក ដូចជាផ្ទាំងថ្មបញ្ឈរ ឬជញ្ជាំង (ប៉ុន្តែមិនចាំបាច់ជាវត្ថុមានលក្ខណៈសាសនាឡើយ[1]) ដោយមានឈ្មោះជនរងគ្រោះ[2] ដែលបានស្លាប់ដោយសារអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម។

**២. ហេតុផល/អត្ថប្រយោជន៍**៖

ក. ជនរងគ្រោះនៃរបបខ្មែរក្រហម បានទទួលការឈឺចាប់ធ្ងន់ធ្ងររួចហើយ មុនពេលបាត់បង់ជីវិត។ ដោយត្រូវបានគេបំភ្លេចចេញពីប្រវត្តិសាស្ត្រ ឬត្រូវបានគេចងចាំត្រឹមជាទិន្នន័យ (ដូចជាចំនួនប្រជាជនដែលស្លាប់សរុប) គឺជាភាពអាម៉ាស់ដែលអាចជៀសវាងបាន។

ខ. មនោគមន៍វិជ្ជាខ្មែរក្រហមគឺថា គ្រប់គ្នាត្រូវតែដូចគ្នា មិនមានវណ្ណៈនៅក្នុងសង្គម គឺក្រីក្រនិងអវិជ្ជាដូចគ្នាទាំងអស់។ ពួកគេផ្តល់តម្លៃតិចតួចបំផុត ចំពោះជីវិតរបស់មនុស្ស ដូច្នេះហើយពួកគេមិនពិបាកអ្វី ក្នុងការសម្លាប់នរណាម្នាក់ឡើយ រួមទាំងទារកនិងកុមារ។ ទាំងអស់នេះហើយដែលនាំទៅដល់ការបាត់បង់លក្ខណៈពិសេសរបស់ជនរងគ្រោះម្នាក់ៗ។ ស្តូបរំលឹកនេះគឺជាមធ្យោបាយ ថែរក្សាជនរងគ្រោះទាំងអស់នេះ នៅក្នុងប្រវត្តិសាស្ត្រ ហើយយ៉ាងហោចណាស់ក៏ជួយស្តារនូវលក្ខណៈជាបុគ្គលរបស់ពួកគាត់ តាមរយៈលក្ខណៈពិសេស នៃការកំណត់អត្តសញ្ញាណយ៉ាងសាមញ្ញបំផុត គឺឈ្មោះរបស់ពួកគាត់។

គ. សាច់ញាតិក្មេងៗរបស់ប្រពន្ធខ្ញុំដែលជាជនជាតិខ្មែរជាច្រើន ក្មួយប្រុស ក្មួយស្រីរបស់យើង និងសូម្បីប្អូនជីដូនមួយក្មេងៗខ្លះ ក៏មិនបានដឹងសូម្បីថា ដូនតារបស់ពួកគេផ្ទាល់មួយចំនួន គឺជាជនរងគ្រោះនៃរបបខ្មែរក្រហម។ ការចងចាំនិងការយល់ដឹងអំពីជនរងគ្រោះទាំងនោះ ប្រហែលជាត្រូវបាត់បង់នៅក្នុងជំនាន់ដែលកើតមុនរបបប្រល័យពូជសាសន៍ ឬកើតក្រោយភ្លាមៗនៃរបបនោះ។

---

[1] https://www.phnompenhpost.com/7days/memorial-plan-prompts-debate-about-victims-and-perpetrators-genocide.

[2] ឧទាហរណ៍ https://www.vvmf.org/About-The-Wall/; https://www.911memorial.org/visit/memorial/names-911-memorial; https://rivcoda.org/victim-services/victims-memorial-wall.

ឃ. ស្ទួបសាធារណៈមិនគិតថ្លៃ គឺជាមធ្យោបាយល្អបំផុត ដើម្បីបង្ហាញឈ្មោះជនរងគ្រោះ ដោយសារតែមនុស្សទូទៅ ប្រហែលជាមិនស្វែងរកព័ត៌មានបែបនេះ ដោយខ្លួនឯងផ្ទាល់នោះទេ។

**៣. <u>ជនរងគ្រោះដែលត្រូវកត់ត្រា</u>៖**

**ក. <u>ពេលវេលាបាត់បង់ជីវិត</u>៖**

១. ដោយសកម្មភាពខ្មែរក្រហម ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩

២. ភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ជាលទ្ធផលផ្ទាល់នៃស្ថានភាព នៅក្នុងពេលកាន់អំណាចនោះ (ដូចជា វប្បូស ការធ្វើការបាក់កម្លាំង កង្វះអាហារូបត្ថម្ភ)

**ខ. <u>ទីកន្លែងដែលបាត់បង់ជីវិត</u>៖** តែនៅទីកន្លែងណាដែល អ.វ.ត.ក បានសម្រេចថាមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាដើម។ ដោយសារតែ អ.វ.ត.ក អនុវត្តនូវគំនិតផ្តួចផ្តើម ទាក់ទងជនរងគ្រោះទាំងអស់នេះ ស្ទួបរំលឹកនេះ គួរគោរពតាមនីតិរដ្ឋដោយត្រូវស្របតាមសាលដីការបស់តុលាការ។

១. ឧទាហរណ៍ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល សម្រេចត្រឹមតែថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់មនុស្ស ប្រហែលជាត្រូវបានប្រព្រឹត្តឡើងទៅលើអ្នករដ្ឋការនិងទាហាន លន់ នល់ ជាង ២៥០ នាក់ នៅទួលពោធិ៍ជ្រៃ នៅចុងខែមេសា ឆ្នាំ១៩៧៥ ដូច្នេះ អ្នករដ្ឋការនិងទាហានទាំងអស់នោះ ដែលត្រូវបានសម្លាប់នៅទីតាំងនោះ មិនគួរត្រូវបានចាត់ទុកថាជា “ជនរងគ្រោះ” សម្រាប់គោលដៅនៃស្ទួបរំលឹកនេះឡើយ។

**៤. <u>លទ្ធភាពនៃប្រភពស្វែងរកឈ្មោះជនរងគ្រោះ</u>៖**

ក. កំណត់ត្រាខ្មែរក្រហម ដូចជានៅទួលស្លែង (មន្ទីរស-២១) កំណត់ត្រាសន្តិបាល[3]។

ខ. កំណត់ត្រា អ.វ.ត.ក

---

[3] https://gsp.yale.edu/read-instructions-tuol-sleng-image-database

គ. មជ្ឈមណ្ឌលឯកសារកម្ពុជា

ឃ. សាធារណជនទូទៅ (សំខាន់បំផុត)៖

១. ផ្សព្វផ្សាយការអំពាវនាវសុំឈ្មោះ តាមមធ្យោបាយដែលអាចធ្វើបាន ដូចជាផ្សាយលើ Facebook និងគេហទំព័ររដ្ឋាភិបាល ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធទូរទស្សន៍និងវិទ្យុ ការប្រកាសដោយស្ថានឯកអគ្គរាជទូតកម្ពុជា អាជ្ញាធរចុះទៅដល់ឃុំ/សង្កាត់/ភូមិ ជាដើម។

២. ផ្តល់ពេលវេលាដល់សាធារណជនចំនួន៦ខែ ដើម្បីបញ្ជូនឈ្មោះសាច់ញាតិរបស់ពួកគេដែលជាជនរងគ្រោះ។

៣. បង្កើតគេហទំព័រ និងមជ្ឈមណ្ឌលទទួលទូរស័ព្ទ ដោយមានបុគ្គលរង់ចាំទទួលឈ្មោះ។

៤. បញ្ហាធំមួយគឺការផ្ទៀងផ្ទាត់យថាភាពនៃព័ត៌មានអំពីជនរងគ្រោះដែលបានបញ្ជូនមក។ វិធានការគ្រប់គ្រងគុណភាពអាចមាន៖

. តម្រូវឲ្យមានអ្នកបញ្ចូលច្រើននាក់ សម្រាប់ឈ្មោះជនរងគ្រោះនីមួយៗ ដើម្បីឲ្យមានការគាំទ្រច្រើនបន្ថែម។

. តម្រូវឲ្យអ្នកបញ្ជូនឈ្មោះ ផ្តល់នូវព័ត៌មានផ្ទាល់ខ្លួនដូចជា លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

. កំណត់ ហើយផ្តល់ព័ត៌មានដល់អ្នកបញ្ជូន អំពីការពិន័យសម្រាប់ការបញ្ជូនព័ត៌មានមិនពិត។

**៥. <u>ការកសាងស្តូបរំលឹក</u>៖**

ក. អ្នកសាងសង់៖ ប្រគល់ជូនអ្នកនៅរស់ពីអំពើប្រល័យពូជសាសន៍ ដែលមានជំនាញគ្រប់គ្រាន់ ឬកូនចៅនៅរស់របស់ជនរងគ្រោះ ដែលការនេះនឹងជួយផ្តល់កិត្តិយសផងដែរដល់ជនរងគ្រោះ

ខ. ទីតាំង៖ នៅរាជធានីភ្នំពេញ ប៉ុន្តែមិនមែននៅទួលស្លែង (មន្ទីរស-២១) ជើងឯក (វាលពិឃាត) ឬទីតាំងប្រល័យពូជសាសន៍ជាក់លាក់ដទៃទៀតឡើយ ដោយសារតែស្តូបរំលឹកនេះ គឺសម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ទាំងអស់ នៅទូទាំងប្រទេសកម្ពុជា។

គ. ប្រសិនបើឈ្មោះរបស់ជនរងគ្រោះ ត្រូវបានរៀបចំតាមលំដាប់អក្ខរក្រម (ភាសាខ្មែរ) គឺមានភាពងាយស្រួលសម្រាប់ការស្វែងរក។

ឃ. ដើម្បីងាយស្រួលក្នុងការកែសម្រួលស្តូបរំលឹកនាពេលក្រោយ សម្រាប់ការបន្ថែមឈ្មោះ ឈ្មោះនីមួយៗអាចឆ្លាក់នៅលើបន្ទះមួយៗដាច់ពីគ្នា ដែលអាចដោះចេញបាន ធ្វើដូច្នេះគឺងាយស្រួលរៀបចំឈ្មោះទាំងនោះឡើងវិញ (ទោះបីថាវាអាចមិនសមស្រប ដោយសារតែចំនួនដ៏ច្រើននៃជនរងគ្រោះ)។ បន្ទះទាំងនោះអាចភ្ជាប់ដោយខ្សៅ/ដង្កៀបជាដើម ពីខាងក្រោយ ឬបិទពីលើដោយបន្ទះផ្លាស្ទិកឬកញ្ចក់ថ្លាពីមុខ។

ង. អាចមានការលំបាកក្នុងការទទួលបាន ឬស្គាល់ព័ត៌មានផ្ទាល់ខ្លួន ដែលអាចកំណត់បានពីអត្តសញ្ញាណជនរងគ្រោះ ក្រៅពីឈ្មោះ ដូចជាទីកន្លែងកំណើត/ស្លាប់ អាយុ ជាដើម ប៉ុន្តែអាចទុកចន្លោះតូចមួយនៅក្បែរឈ្មោះ ដើម្បីដាក់រូបថត ប្រសិនបើមាន (ដូចជាជនរងគ្រោះនៅទួលស្លែង)

ច. ឈ្មោះជនរងគ្រោះ អាចដាក់ជាក្រុម ប្រសិនបើមានព័ត៌មានគ្រប់គ្រាន់ អំពីទីកន្លែងពួកគេស្លាប់។ ការដាក់ផ្លាកក្រុមក៏អាចជួយផងដែរ ដល់ក្រុមដែលមានភាពចម្រូងចម្រាស់ ដូចជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានសម្លាប់នៅក្នុងពេលបោសសម្អាតផ្ទៃក្នុង[4]។

ឆ. ដោយសារតែមិនអាចស្គាល់ឈ្មោះជនរងគ្រោះទាំងអស់ គួរតែមានកន្លែងលេចធ្លោមួយសម្រាប់ “ជនរងគ្រោះដែលមិនស្គាល់ឈ្មោះ” ប្រហែលគ្នានឹងស្តូបរំលឹក “ទាហានមិនស្គាល់ឈ្មោះ” ដែរ។

---

[4] https://www.phnompenhpost.com/7days/memorial-plan-prompts-debate-about-victims-and-perpetrators-genocide.